# ចូរបង្ហាញឲ្យឃើញ!

ថ្នាក់ទី៣ - សិល្បៈភាសាអង់គ្លេស - អក្សរសិល្ប៍ 3.1

| ស្តង់ដារមុខវិជ្ជាស្នូល | ជាមូលដ្ឋាន ត្រង់នេះមានន័យថា កូនរបស់អ្នក ... |
|---|---|
| RL.3.1 សួរ និងឆ្លើយសំណួរដើម្បីបង្ហាញស្វែងយល់អត្ថបទ។ សូមអានអត្ថបទឲ្យបានច្បាស់លាស់ដើម្បីឆ្លើយសំណួរ។ | សួរ និងឆ្លើយសំណួរដោយផ្អែកលើអត្ថបទ។ |

## ព័ត៌មានគោលៈ

វាពិតជាសំខាន់ណាស់សម្រាប់កូនរបស់អ្នកដែលអាចចោទសួរ និងឆ្លើយសំណួរ នៅពេលពួកគេកំពុងអាន។ សំខាន់ជាងនេះទៀត នៅពេលកូនរបស់លោកអ្នកឆ្លើយសំណួរ សូមប្រាកដថា ពួកគេអាចរកចម្លើយតាមរយៈការអានអត្ថបទឡើងវិញ។

*ឧទាហរណ៍:*

**ឪពុកៈ** តើព្រះអង្គម្ចាស់ដោះស្រាយបញ្ហារបស់ទ្រង់ និងរកស៊ីនឌឺរឡាឃើញដោយរបៀបណា?

**កូនៈ** ទំព័រទី២២ និយាយថា ព្រះអង្គម្ចាស់ និងសេនារបស់ទ្រង់បានយាងពីផ្ទះមួយទៅផ្ទះមួយរបស់ស្រីៗ ដែលត្រូវបានអញ្ជើញឲ្យចូលរួមក្នុងពិធីជប់លៀង។ ដំបូង ព្រះអង្គយាងទៅព្រះអង្គម្ចាស់ក្សត្រី ក្រោយមក ទៅមហេសីរបស់ស្តេចក្រាញ់នានា និងបន្ទាប់ទៀត ទៅរកស្រីៗទាំងនោះ។ ចុងក្រោយ ព្រះអង្គ បានមកដល់ផ្ទះម្តាយចុង ហើយបានរកឃើញនាងស៊ីនឌឺរឡា។

## សកម្មភាពៈ

1. លេងល្បែងធម្មតានេះជាមួយកូនរបស់អ្នក។
2. ឲ្យកូនរបស់លោកអ្នកអានឲ្យបានឮៗ ដោយប្រើសំណង់ឃ្លា។
3. នៅពេលកូនរបស់លោកអ្នកកំពុងអាន (បន្ទាប់ពី២ ទៅ៤ ទំព័រ) សួរពួកគេអំពីអ្វីដែលពួកគេបានអាន។ ចូរប្រើសំណួរស្វែងយល់ (Comprehension Questions) ដែលអាចរកបាននៅផ្នែកធនធាន (Resource) ។
4. ឲ្យកូនរបស់អ្នកនិយាយថា "ទំព័រទី _________ និយាយថា ___________"
5. នៅពេលណាកូនរបស់អ្នកមានកិច្ចការផ្ទះត្រូវអាន ត្រូវប្រាប់ពួកគេនូវកន្លែងដែលអាចរកចម្លើយនៅក្នុងអត្ថបទ។

## ផ្នែកបន្ថែមៈ

សកម្មភាពនេះអាចត្រូវបានធ្វើបន្តថែមទៀតដោយប្រើកុំព្យូទ័រ។ ប្រសិនកូនរបស់អ្នកមានសំណួរអំពីប្រធានបទជាក់លាក់ណាមួយ ឲ្យពួកគេប្រើអ៊ីនធឺណែតដើម្បីស្រាវជ្រាវរកចម្លើយ។ ក្រោយមកទៀត ឲ្យពួកគេចែករំលែកចម្លើយ និងកន្លែងដែលពួកគេរកព័ត៌មាន។

## អ្វីដែលអ្នកត្រូវការ (សម្ភារ)ៈ

☐ សៀវភៅ

☐ សំណួរស្វែងយល់

## ធនធានៈ
# សំណួរស្វែងយល់ដែលមាតាបិតាអាចសួរ

1. មកទល់និងពេលនេះ តើមានអ្វីបានកើតឡើងនៅក្នុងសាច់រឿង?
2. តើអ្នកគិតថា នឹងមានអ្វីកើតឡើងបន្ទាប់ទៀត?
3. តើអ្នកគិតថា ចំណងជើងសៀវភៅនេះសមរម្យដែរ ឬអត់? តើអ្នកគួរហៅវាថាដូចម្តេច?
4. តើវាគឺជាសៀវភៅរឿងបែបប្រឌិត ឬមិនមែនបែបប្រឌិត?
5. តើរឿងកើតឡើងនៅកន្លែងណា?
6. តើរឿងនេះភាគច្រើននិយាយពីនរណា?
7. តើនរណាជាតួអង្គដែលអ្នកពេញចិត្ត? ហេតុអ្វី? តើនរណាជាតួអង្គដែលអ្នកស្អប់បំផុត? ហេតុអ្វី?
8. តើអ្វីជាបញ្ហាសំខាន់នៅក្នុងរឿងនេះ? តើបញ្ហានោះត្រូវបានដោះស្រាយដោយរបៀបណា?
9. តើយោបល់របស់អ្នកអំពីតួអង្គនេះផ្លាស់ប្តូរដែរឬទេ នៅក្នុងសាច់រឿង? ដោយរបៀបណា? ហេតុអ្វី?
10. ចូររកចំណុចពីរដែលអ្នកនិពន្ធសរសេរអំពីតួអង្គនេះ ដែលធ្វើឲ្យគាត់អាចចូលចិត្ត ឬមិនអាចចូលចិត្ត?
11. ប្រសិនអ្នកបានជួបតួអង្គម្នាក់ក្នុងចំណោមតួអង្គជាច្រើននៅក្នុងរឿង តើអ្នកនឹងនិយាយអ្វីខ្លះទៅគាត់?
12. តើផ្នែកណាមួយនៃសាច់រឿងដែលអ្នកចូលចិត្ត និងមិនចូលចិត្ត? ហេតុអ្វី?
13. តើអ្នកនឹងផ្លាស់ប្តូរផ្នែកណាមួយនៃរឿងដែរ ឬអត់? ដោយរបៀបណា?
14. តើអ្នកនឹងផ្លាស់ប្តូរតួអង្គណាមួយដែរឬអត់? ដោយរបៀបណា?
15. តើផ្នែកណាមួយនៃសាច់រឿងបង្ហាញចំណុចកំប្លែងបំផុត ខ្លាចបំផុត ក្រៀមក្រំបំផុត និងសប្បាយបំផុត? ចូររកភស្តុតាងខ្លះនៅក្នុងអត្ថបទដើម្បីគាំទ្រយោបល់របស់អ្នក។
16. តើឈុតនៃសាច់រឿងយឺត ឬលឿន? ចូរស្វែងរកភស្តុតាងខ្លះនៅក្នុងអត្ថបទសម្រាប់គាំទ្រទស្សនៈរបស់អ្នក។
17. ប្រសិនអ្នកនិពន្ធបានបញ្ចូលកថាខណ្ឌមួយផ្សេងទៀតមុនរឿងចាប់ផ្តើម តើអ្នកគិតថា កថាខណ្ឌនោះនឹងនិយាយអំពីអ្វី?
18. តើអ្នកចង់អានសៀវភៅមួយផ្សេងទៀតរបស់អ្នកនិពន្ធនេះទេ? ហេតុអ្វី?
19. ប្រសិនអ្នកអាចបន្ថែមទំព័រមួយទៀតទៅក្នុងសៀវភៅ តើអ្នកនឹងសរសេរអំពីអ្វី? (ត្រង់នេះ យើងចង់ឃើញថាតើក្មេងអាចចំណាំគម្រូ ឬសម្លេងដែលចាប់ផ្តើមជាមួយពាក្យទាំងអស់នោះដែរ ឬទេ)
20. តើអ្នកចូលចិត្តអ្វីខ្លះ អំពីរឿងនេះ?
21. តើរឿងនេះបានរំលឹកអ្នកអំពីអ្វីមួយនៅក្នុងឆាកជីវិតរបស់អ្នកដែរ ឬអត់?
22. តើរឿងនេះរំលឹកអ្នកអំពីសៀវភៅដែលអ្នកបានធ្លាប់បានអានដែរ ឬអត់?
23. ហេតុអ្វីអ្នកគិតថា អ្នកនិពន្ធនិពន្ធសៀវភៅនេះ?
24. តើមានតួអង្គណាម្នាក់ ដែលបានរំលឹកអ្នកអំពីខ្លួនអ្នក ឬបុគ្គលណាម្នាក់ដែលអ្នកស្គាល់ដែរ ឬទេ?
25. តើអ្វីគឺជាចំណុចសំខាន់បំផុត ដែលអ្នកចាំពីសាច់រឿងនេះ?